ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

| |
|---|
| មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី ខេត្តបន្ទាយមានជ័យ |
| ចូល — លេខ : ៥១៧ |
| ថ្ងៃទី ២៧/៧/០៥ ម៉ោង...... |
| បញ្ជូន ................ |

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ: ១០២៩ ដនស/សជ

ភ្នំពេញ. ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០០៥

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

## ជំរាបមក

## អស់លោក លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី គ្រប់ខេត្ត-ក្រុង

**កម្មវត្ថុ** : អំពីការផ្ដល់ពត៌មាន និង ឯកសារដីធ្លី ដែលពាក់ព័ន្ធនឹងដីព្រៃ

**យោង** : សេចក្ដីជូនដំណឹងលេខ ១០៧៤ សជណ/កស ចុះថ្ងៃទី ០៥/០៧/០៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ សុំអស់លោក លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី គ្រប់ខេត្ត-ក្រុង ធ្វើការណែនាំទៅគ្រប់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលគ្រប់ស្រុក-ខ័ណ្ឌ ក្រោមឱវាទ ឱ្យអនុវត្តនូវស្មារតីនៃសេចក្ដីជូនដំណឹងនេះ ដោយសហការជាមួយរដ្ឋបាលព្រៃឈើ ដើម្បីកំណត់តំបន់ព្រៃឈើ ។ ផ្អែកលើនេះ ត្រូវស្រង់ពត៌មាន និង ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ និង វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ (ប្រសិនបើមាន) ដែលស្ថិតនៅក្នុងតំបន់នោះ ដើម្បីចម្លងជូនអនុគណៈកម្មាធិការ ខេត្ត-ក្រុង ទប់ស្កាត់ បង្ក្រាប និង លុបបំបាត់ការកាប់រាន ដុត ឈូសឆាយ និង ហ៊ុំព័ទ្ធដីព្រៃឈើ និង រដ្ឋបាលព្រៃឈើប្រចាំខេត្ត-ក្រុង ។

ក្នុងការវិនិច្ឆ័យកំណត់តំបន់ព្រៃ ប្រសិនបើមានបញ្ហាមិនឯកភាពគ្នា ត្រូវរាយការណ៍សុំយោបល់ប្រធានគណៈកម្មាធិការប្រើប្រាស់ និង បែងចែកដីខេត្ត-ក្រុង ដើម្បីប្រធានគណៈកម្មាធិការប្រើប្រាស់ និង បែងចែកដីខេត្ត-ក្រុង ធ្វើការសំរបសំរួលជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីស្រុក-ខ័ណ្ឌ ក្រុមប្រឹក្សាឃុំ-សង្កាត់ និង ប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងតំបន់ផ្ទាល់ ដើម្បីរកការឯកភាពគ្នាដោះស្រាយ ។ ក្នុងករណីរកការឯកភាពគ្នាមិនឃើញ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ត្រូវស្នើសុំប្រធានគណៈកម្មាធិការប្រើប្រាស់ និង បែងចែកដី ខេត្ត-ក្រុង បញ្ជូនសំណុំរឿងនោះ ទៅសុំយោបល់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

អាស្រ័យហេតុនេះ សូមអស់លោក លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីគ្រប់ខេត្ត-ក្រុង ធ្វើការផ្សព្វផ្សាយដល់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក-ខ័ណ្ឌ និងមន្ត្រីក្រោមឱវាទ ឱ្យអនុវត្តសេចក្ដីជូនដំណឹងនេះ ឱ្យមានប្រសិទ្ធភាពក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

**ចម្លងជូន :**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- ក្រសួងបរិស្ថាន
- គ្រប់សាលាខេត្ត-ក្រុង
- ឯកសារ - កាលប្បវត្តិ

អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខ័ណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel : (855) 023 215 659- 215 660, Fax : (855) 023 215 277, e-mail : [illegible] Camnet Com Kh